សួស្តី ដែលនៅក្នុងរូបភាពនេះ គឺយើងនឹងនិយាយអំពីការញ៉ាំត្រីអាំង។ អញ្ចឹងការញ៉ាំត្រីអាំង
ដែលជាទូទៅ ត្រីគឺមានច្រើនប្រភេទ ហើយត្រីគឺយើងអាចធ្វើជាមុខម្ហូបបានយ៉ាងច្រើនផងដែរ
ដែលនៅក្នុងប្រទេសកម្ពុជា យើងអាចយកត្រីមក ជាទូទៅយើងយកត្រីមកអាំង ឬក៏មកចៀន
ទៅតាមចំណង់ចំណូលចិត្ត និងទៅតាមអ្វីដែលយើងចង់ញ៉ាំ។

ដែលជាក់ស្តែង នៅក្នុងរូបភាពទី ១ នៅក្នុងរូបភាពទី ១ យើងឃើញមានបុរសម្នាក់
កំពុងតែដើរទៅផ្ទះ អញ្ចឹងបានន័យថាគាត់កំពុងតែដើរមកពីកន្លែងធ្វើការ
ឬក៏ដើរមកពីការដើរកម្សាន្តជាមួយនឹងមិត្តភក្តិ ឬក៏គាត់ទើបតែត្រលប់មកពីការហាត់ប្រាណវិញ
អញ្ចឹងគាត់កំពុងតែដើរតាមផ្លូវសំដៅទៅផ្ទះ ដែលគាត់ដើរបណ្តើរ គិតទៅដល់ផ្ទះរបស់គាត់បណ្តើរ
ថាគាត់ជិតដើរ ជិតដល់ផ្ទះហើយ ដែលយើងឃើញបុរសម្នាក់ហ្នឹង គាត់មានអាយុប្រហែលជា ២៣
ឆ្នាំ។ អញ្ចឹងគាត់អាយុប្រហែលជា ២៣ ឆ្នាំ ដែលគាត់ពាក់អាវលឿង ដៃខ្លី ខោជើងវែងពណ៌ស
ហើយគាត់ពាក់ស្បែកជើងប៉ាតាពណ៌ទឹកក្រូច អញ្ចឹងបុរសម្នាក់នោះ គាត់ដើរ
អាចត្រលប់មកពីកន្លែងហាត់ប្រាណ ឬក៏គាត់អាចនឹងទើបតែត្រលប់មកពី[ការ]
កន្លែងធ្វើការរបស់គាត់។ ដូច្នេះគាត់ដើរត្រលប់ទៅផ្ទះ ដែលយើងឃើញនៅខាងក្រោយគាត់
គឺមានស្រមោលនៃទីក្រុង បានន័យថាគាត់ក៏ជាមនុស្សដែលរស់នៅទីក្រុងដែរ
អញ្ចឹងគាត់អាចនឹងដើរទៅទីក្រុង ឬក៏ទើបផ្ទះរបស់គាត់ដែលនៅទីក្រុង
ដើម្បីទៅសម្រាកនៅផ្ទះរបស់គាត់ ទទួលទានអាហារ ជាមួយនឹងមិត្តស្រីរបស់គាត់
ឬក៏ជាមួយនឹងគ្រួសាររបស់គាត់បាន។

បន្ទាប់មកទៀតរូបភាពទី ២ នៅក្នុងរូបភាពទី ២ យើងឃើញថា
បន្ទាប់ពីគាត់ដើរបានបន្តិចក្រោយមក អញ្ចឹងនៅពេលដែលបុរសម្នាក់នោះ
គាត់បានដើរបន្តិចក្រោយមក យើងឃើញគាត់ដើរមកដល់កន្លែងលក់ត្រីអាំងមួយកន្លែង
អញ្ចឹងយើងឃើញបុរសម្នាក់នោះ គាត់បានឈរសម្លឹងទៅលើកន្លែងលក់ត្រីអាំង ដែលនៅចិញ្ចើមផ្លូវ
អញ្ចឹងជាទូទៅនៅកម្ពុជាគឺយើងមានការលក់ត្រីអាំងនៅតាមចិញ្ចើមផ្លូវជាច្រើនកន្លែងផងដែរ
ដែលយើងឃើញគេអាំងមានត្រីច្រើនប្រភេទ ដែលមានអ្នកខ្លះអាំងត្រីដៀប អ្នកខ្លះអាំងត្រីរ៉ស់
អ្នកខ្លះទៀតអាំងត្រីក្រហម អ្នកខ្លះទៀតអាំងត្រីអណ្តែងជាដើម
អញ្ចឹងត្រីមានច្រើនប្រភេទដែលប្រជាជនកម្ពុជាចូលចិត្តអាំង។ ដែលយើងឃើញនៅក្នុងរូបភាពទី ២
នេះ គឺមានចង្កើរត្រីមួយ ដែលគេកំពុងតែអាំងនៅក្រោមឆត្រ អញ្ចឹងគឺគេមានចង្ក្រាន
ការអាំងត្រីគឺត្រូវមានចង្ក្រាន ដែលចង្ក្រាននោះគឺយើងប្រើធ្យូងដើម្បីឲ្យមានរងើកភ្លើង។
អញ្ចឹងជាទូទៅការអាំងត្រីគឺយើងអត់ប្រើអុសនោះទេ ព្រោះអុសគឺជាឈើ អញ្ចឹងឈើ
នៅពេលដែលត្រូវភ្លើង គឺឆេះ មានអណ្តាតភ្លើង អញ្ចឹងវាធ្វើឲ្យត្រីអត់អាចអាំងបាននោះទេ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

វាអាចខ្លោច ដូច្នេះយើងត្រូវប្រើធ្យូង អញ្ចឹងធ្យូង នៅពេលដែលត្រូវភ្លើងគឺវាអត់មានអណ្ដាតភ្លើងទេ
គឺវាមានតែរងើកភ្លើង អញ្ចឹងវាមានរងើកភ្លើង ដូច្នេះវាអត់អាចធ្វើឲ្យត្រីខ្លោចបានទេ
អញ្ចឹងយើងអាចអាំងត្រីបានឆ្អិនល្អ ដែលនៅក្នុងនេះយើងឃើញមានចង្អេីរមួយធំ
នៅលើចង្ក្រានអាំងត្រី អញ្ចឹងគេអាំងត្រីនៅលើចង្ក្រាន
ហើយដាក់ចង្អេីរនៅលើចង្ក្រាននោះឲ្យខ្ពស់ផុតពីភ្លើងបន្តិច
ហើយបន្ទាប់មកគេដាក់ត្រីនៅលើចង្អេីរនោះ ដែលជាក់ស្ដែងនៅក្នុងរូបភាពនេះ
យើងឃើញគេកំពុងតែអាំងត្រីចំនួនបីនៅលើចង្អេីរដែលធំមួយ ហើយមានបុរសម្នាក់
គាត់កំពុងតែអង្គុយនៅក្បែរចង្ក្រានអាំងត្រីនោះ ដែលគាត់ជាអ្នកលក់
អញ្ចឹងយើងឃើញគាត់អាំងបណ្ដើរ ហើយមានផ្សែងហុយចេញពីចង្ក្រានគាត់បណ្ដើរ
បានន័យថាត្រីនោះគឺនៅក្ដៅ ហើយមានហុយក្លិនឈ្ងុយ មកតាមបរិយាកាស ឬក៏នៅក្នុងខ្យល់
អញ្ចឹងធ្វើឲ្យមានអ្នកដំណើរគឺគាត់ចង់ញុំាដោយសារតែក្លិនឈ្ងុយនៃត្រី
ដែលយើងឃើញនៅលើចង្ក្រាន គឺយើងឃើញមានឆត្រមួយផងដែរ
អញ្ចឹងឆត្រនោះគឺជាឆត្រមួយដើម្បីការពារទឹកភ្លៀង ឬក៏ទឹកសន្សើមផ្សេងៗ កុំឲ្យធ្លាក់ទៅលើត្រី
ព្រោះប្រសិនបើត្រីអាំងត្រូវទឹកភ្លៀង គឺធ្វើឲ្យសាច់របស់វាខូច វាអាចធ្វើឲ្យទន់ពេក ឬក៏មិនឆ្ងាញ់
ដូច្នេះអ្នកលក់គាត់ត្រូវបាំងថ្ងៃបាំងភ្លៀង កុំឲ្យទទឹក ទៅទទឹកនឹងត្រីអាំង ម្យ៉ាងវិញទៀត
ប្រសិនបើចង្ក្រានអាំងត្រីត្រូវទឹក វាអាចធ្វើឲ្យរលត់ភ្លើង អញ្ចឹងធ្វើឲ្យត្រីអាំងរបស់គាត់អត់ឆ្អិននោះទេ
ដូច្នេះគាត់ត្រូវការពារ។ អញ្ចឹងបុរសដែលពាក់អាវលឿង ដែលមានវ័យ ២៣ ឆ្នាំហ្នឹង
គាត់បានដើរមកដល់កន្លែងលក់ត្រីអាំងមួយកន្លែង ដែលអ្នកលក់ គាត់ពាក់អាវដៃខ្លីពណ៌ស្វាយ
ខោជើងវែងពណ៌ស ហើយគាត់ពាក់ស្បែកជើងប៉ូពណ៌ខ្មៅ
អង្គុយលក់នៅក្បែរចង្ក្រានអាំងត្រីនោះផងដែរ។

បន្ទាប់មកទៀតរូបភាពទី ៣ នៅក្នុងរូបភាពទី ៣ យើងឃើញថា
បន្ទាប់ពីគាត់ឃើញកន្លែងលក់ត្រីអាំង បុរសដែលពាក់អាវលឿងដៃខ្លីនោះ
គាត់ក៏បានចូលទៅដល់កន្លែងលក់ត្រីអាំង បានន័យថាគាត់ចូលទៅជិតនឹងចង្ក្រានលក់ត្រីអាំង
ហើយសួរតម្លៃទៅអ្នកលក់អំពីតម្លៃនៃត្រីអាំងនោះ អញ្ចឹងដោយសារតែត្រីអាំងគឺ
យើងអាំងមានច្រើនប្រភេទ យើងមានត្រីច្រើនប្រភេទខុសៗគ្នា
អញ្ចឹងតម្លៃនៃត្រីអាំងគឺវាខុសគ្នាទៅតាមប្រភេទត្រីផងដែរ ដោយត្រីខ្លះ ដូចជាត្រីដៀប
និងត្រីរ៉ស់ជាដើម ជាត្រីធំៗ ដូច្នេះគឺវាមានតម្លៃថ្លៃ ចំណែកឯត្រីផ្សេងទៀតដូចជាត្រីអណ្ដែង
ឬក៏ត្រីក្រហម អញ្ចឹងគឺវាមានតម្លៃថោកជាងត្រីដៀបត្រីរ៉ស់បន្តិច
អញ្ចឹងពេលខ្លះគឺគាត់អាចចង់បានត្រីដែលថោក ពេលខ្លះគាត់ចង់បានត្រីដែលថ្លៃ
ព្រោះត្រីដែលថ្លៃគឺមានរសជាតិឆ្ងាញ់ ដូច្នេះដើម្បីឲ្យដឹងថាតម្លៃប៉ុន្មាន បុរសម្នាក់នោះ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

គាត់ក៏បានចូលមកសួរអ្នកលក់ ដោយគាត់ចង្អុលទៅលើត្រីមួយ អញ្ចឹងយើងឃើញរូបភាពទី ៣ នេះ
គឺបុរសម្នាក់នោះ គាត់បានលើកដៃចង្អុល ចង្អុលទៅរូបត្រីមួយ ទៅលើត្រីមួយ
ហើយសួរទៅអ្នកលក់ថាតម្លៃប៉ុន្មាន អញ្ចឹងអ្នកលក់
គាត់ក៏បានឆ្លើយប្រាប់តម្លៃទៅដល់បុរសម្នាក់នោះយ៉ាងយកចិត្តទុកដាក់
ដោយគាត់មើលពិនិត្យមើលត្រី មើលទំហំត្រី
ហើយគាត់បានឆ្លើយប្រាប់តម្លៃទៅដល់បុរសម្នាក់នោះភ្លាម។

បន្ទាប់មកទៀតរូបភាពទី ៤ នៅក្នុងរូបភាពទី ៤ យើងឃើញថា
បន្ទាប់ពីគាត់បានទិញត្រីចំនួនមួយក្បាលហើយ បន្ទាប់មកបុរសម្នាក់នោះ
គាត់ក៏បានប្រាប់ទៅអ្នកលក់ គាត់បានលើកដៃជាសញ្ញាឡើងពីរ
បានន័យថាគាត់លើកដៃម្រាមពីរឡើង ដៃស្តាំរបស់គាត់គឺលើកម្រាមពីរ ដើម្បីប្រាប់ទៅអ្នកលក់ថា
គាត់ត្រូវការបាយពីរកញ្ចប់ អញ្ចឹងដោយសារតែនៅផ្ទះគាត់មានគ្នាចំនួនពីរនាក់
ប្រហែលជាគាត់មានគ្នាចំនួនពីរនាក់ ដូច្នេះគាត់ទិញបាយដំណើបចំនួនពីរកញ្ចប់
ប៉ុន្តែនៅក្នុងប្រទេសកម្ពុជាជាទូទៅយើងញ៉ាំបាយធម្មតា គឺយើងអត់ញ៉ាំបាយដំណើបទេ
ដោយសារតែបាយដំណើបគឺវារៀងស្អិត អញ្ចឹងវាពិបាកញ៉ាំ ដូច្នេះគឺយើងញ៉ាំបាយអង្ករខ្សាយ
គេហៅថាអង្ករខ្សាយ អញ្ចឹងជាបាយមួយដែលមានពណ៌ស ហើយអត់សូវស្អិតនោះទេ
ដូច្នេះនៅកម្ពុជាគឺយើងញ៉ាំបាយអង្ករខ្សាយ គឺយើងអត់ញ៉ាំបាយដំណើបទេ។ អញ្ចឹងបុរសម្នាក់នោះ
គាត់បានប្រាប់ទៅអ្នកលក់ដើម្បីទិញបាយចំនួនពីរកញ្ចប់បន្ថែមទៀត បន្ទាប់ពីគាត់ទិញត្រីហើយ
ដូច្នេះគាត់បានលើកដៃចំនួនពីរឡើង
ដើម្បីប្រាប់ទៅអ្នកលក់ឲ្យអ្នកលក់ខ្ចប់បាយចំនួនពីរកញ្ចប់យកមកឲ្យគាត់ ដែលរូបភាពទី ៤ នេះ
យើងឃើញអ្នកលក់ គាត់បានកាន់បាយចំនួនពីរកញ្ចប់យកមកឲ្យបុរសម្នាក់នោះ
ដែលគាត់លើកបាយចំនួនពីរកញ្ចប់ឡើង ហើយគាត់បានចង្អុលទៅកាន់កញ្ចប់បាយទាំងនោះ
ដើម្បីប្រាប់ទៅដល់បុរសម្នាក់នោះទៅតាមតម្រូវការរបស់គាត់ អញ្ចឹងគាត់កាន់បាយពីរកញ្ចប់
ដែលបាយទាំងពីរកញ្ចប់គឺដាក់នៅក្នុងកញ្ចប់មួយៗ គឺ មួយកញ្ចប់មួយ មួយកញ្ចប់មួយ
សម្រាប់មនុស្សពីរនាក់ អញ្ចឹងបាយពីរកញ្ចប់សម្រាប់មនុស្សពីរនាក់។

បន្ទាប់មកទៀតរូបភាពទី ៥ នៅក្នុងរូបភាពទី ៥ យើងឃើញថា បន្ទាប់ពីអ្នកលក់ អ្នកទិញ
គាត់បានទិញត្រីចំនួនមួយហើយ អញ្ចឹងអ្នកលក់ គាត់បានប្រញាប់រួសរាន់ខ្ចប់ត្រីនោះឲ្យភ្ញៀវ
អញ្ចឹងនៅក្នុងរូបភាពនេះយើងឃើញអ្នកលក់បានយកត្រីដែលអាំងឆ្អិនរួច អញ្ចឹងត្រីអាំងឆ្អិន
គាត់បានយកខ្ចប់នឹងក្រដាសកាសែត អញ្ចឹងដោយសារតែគាត់ចង់ការពារបរិស្ថានផង
អញ្ចឹងគាត់អត់ប្រើថង់ប្លាស្ទិកនោះទេ ព្រោះថាប្រើថង់ប្លាស្ទិក ពេលខ្លះវាអាចប៉ះពាល់ដល់បរិស្ថាន

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ដោយសារតែវាជាសារធាតុគីមី ដូច្នេះនៅពេលដែលយើងបោះចោលថង់ប្លាស្ទិកផ្តេសផ្តាស
វាអាចហូរទៅក្នុងលូ ឬក៏ហូរទៅកប់ទៅក្នុងដី វាអាចធ្វើឲ្យប៉ះពាល់ដល់បរិស្ថានដូចជាស្ទះលូ
ឬក៏ដីខ្វះជីវៈជាតិជាដើម។ អញ្ចឹងដើម្បីឲ្យបរិស្ថានស្អាត ដើម្បីឲ្យបរិស្ថានស្អាត
យើងត្រូវប្រើប្រាស់ក្រដាសកាសែតវិញ អញ្ចឹងជាក់ស្តែងបុរសនោះ ដែលជាអ្នកលក់
គាត់បានប្រើប្រាស់ក្រដាសកាសែត ដើម្បីខ្ចប់ត្រីរបស់គាត់ឲ្យទៅភ្ញៀវ
ដែលគាត់អត់ប្រើប្រាស់ថង់ប្លាស្ទិកនោះទេ ម្យ៉ាងក្រដាសកាសែតគឺមានតម្លៃថោក
ដូច្នេះគាត់អាចចំណេញបានច្រើន ប្រសិនបើគាត់ប្រើប្រាស់ក្រដាសកាសែតដើម្បីខ្ចប់ត្រី
អញ្ចឹងគាត់អាចចំណេញច្រើនផងដែរ
ដោយយើងឃើញគាត់បានរុំត្រីចូលទៅក្នុងក្រដាសកាសែតមួយសន្លឹក។

បន្ទាប់មកទៀតរូបភាពទី ៦ នៅក្នុងរូបភាពទី ៦ យើងឃើញថា
បន្ទាប់ពីគាត់បានទិញត្រីនិងបាយចំនួនពីរកញ្ចប់រួចរាល់ហើយ
គាត់ក៏បានយកបាយនិងត្រីដាក់ចូលទៅក្នុងថង់ធំមួយ អញ្ចឹងគាត់ខ្ចប់ត្រីនៅក្នុងក្រដាសកាសែត
ហើយបាយខ្ចប់នៅក្នុងកញ្ចប់តូចៗ អញ្ចឹងដើម្បីយួរទៅផ្ទះឲ្យមានភាពងាយស្រួល
គាត់ក៏បានមានថង់ក្រណាត់តូចមួយ ឬក៏ថង់ក្រដាស យើងហៅថាថង់បរិស្ថានមួយ
ដែលយើងហៅថាថង់ក្រណាត់ អញ្ចឹងគាត់អាចយកថង់ក្រណាត់ធំមួយ
មកដាក់ត្រីនិងបាយរបស់គាត់ចូលទៅក្នុងនោះ ដែលយើងឃើញនៅក្នុងថង់ក្រណាត់នោះ
គឺយើងឃើញមានក្រដាសកាសែតដែលរុំត្រីអម្បាញ់មិញចំនួនមួយ និងមានបន្លែផងដែរ
បន្លែប្រហែលជាបន្លែទុកញ៉ាំជាមួយនឹងត្រីអាំង ឬក៏មានម្ហូបផ្សេងទៀតផងដែរ
ហើយនៅក្នុងនោះគឺយើងឃើញមានបាយចំនួនពីរកញ្ចប់ អញ្ចឹងបន្ទាប់ពីគាត់ទិញរួចរាល់ហើយ
គាត់ក៏បានដាក់ទឹកជ្រលក់ចូលទៅក្នុងនោះផងដែរ ដោយសារតែត្រីអាំងភាគច្រើនគឺជាត្រីសាប
គឺវាមានរសជាតិសាប ដូច្នេះយើងអត់អាចញ៉ាំទទេបានទេ គឺអត់ឆ្ងាញ់
អញ្ចឹងដើម្បីឲ្យវាមានរសជាតិឆ្ងាញ់ យើងត្រូវញ៉ាំជាមួយនឹងទឹកជ្រលក់
ដែលជាក់ស្តែងយើងឃើញនៅក្នុងរូបភាពទី ៦ នេះ គឺគាត់បានទិញទឹកជ្រលក់មួយកញ្ចប់ផងដែរ
ប៉ុន្តែជាទូទៅទឹកជ្រលក់ត្រីគឺយើងអត់ចាំបាច់ទិញទេ គឺនៅ[ក្នុង]កម្ពុជាគឺយើង
នៅពេលដែលយើងទិញត្រី គឺអ្នកលក់តែងតែឲ្យទឹកជ្រលក់មកជាមួយតែម្តង ដើម្បីជ្រលក់ជាមួយត្រី
អញ្ចឹងនៅក្នុងរូបភាពទី ៦ យើងឃើញគាត់ដាក់ទឹកជ្រលក់ត្រីចូល[ទៅ]មួយកញ្ចប់
ចូលទៅក្នុងថង់ធំរបស់គាត់ដើម្បីយួរទៅផ្ទះ។

បន្ទាប់មកទៀតរូបភាពទី ៧ នៅក្នុងរូបភាពទី ៧ យើងឃើញថា បន្ទាប់ពីគាត់បានកុម្ម៉ង់ទិញបាយ
និងត្រី ជាមួយនឹងបន្លែ និងទឹកជ្រលក់រួចរាល់ហើយ គាត់បានខ្ចប់ចំណីអាហារទាំងនោះ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ចូលទៅក្នុងថង់ធំមួយរួចហើយ អញ្ចឹងគាត់ក៏បានប្រគល់លុយទៅឲ្យអ្នកលក់
អញ្ចឹងជាទូទៅគឺអ្នកលក់ត្រូវឲ្យលុយ ត្រូវឲ្យរបស់ទៅដល់អ្នកទិញ
ចំណែកឯអ្នកទិញត្រូវប្រគល់លុយទៅឲ្យអ្នកលក់ថ្លៃរបស់។
ដែលជាក់ស្តែងគឺបុរសដែលពាក់អាវលឿង គាត់បានទិញត្រី ទិញបាយ ជាមួយនឹងទឹកជ្រលក់
ជាមួយនឹងបន្លែផ្សេងៗ ពីបុរសដែលជាអ្នកលក់ ដែលពាក់អាវពណ៌ស្វាយ
អញ្ចឹងបុរសដែលពាក់អាវលឿងគឺជាអ្នកទិញ ឬក៏ជាអតិថិជន
ដូច្នេះគាត់ត្រូវប្រគល់លុយទៅឲ្យបុរសដែលជាអ្នកលក់ អញ្ចឹងយើងឃើញនៅក្នុងរូបភាពនេះគឺ
បុរសដែលពាក់អាវលឿងកំពុងតែប្រគល់លុយ ឬក៏សាច់ប្រាក់ទៅឲ្យបុរសដែលពាក់អាវពណ៌ស្វាយ
ហើយបុរសដែលពាក់អាវពណ៌ស្វាយដែលជាអ្នកលក់
ក៏បានលូកដៃទទួលយកប្រាក់ថ្លៃត្រីរបស់គាត់ផងដែរ
ដូច្នេះពួកគាត់គឺទូទាត់គ្នាដោយប្រើសាច់ប្រាក់។

បន្ទាប់មកទៀតរូបភាពទី ៨ នៅក្នុងរូបភាពទី ៨ បន្ទាប់ពីគាត់ចាកចេញពីកន្លែងលក់ត្រីមក
អញ្ចឹងគាត់បានបន្តដំណើរមកមុខទៀត
អញ្ចឹងគាត់ដើររហូតឆ្ពោះមកមុខលុះគាត់ដើរបានមួយសន្ទុះក្រោយមក
គាត់បានដើរមកដល់ផ្ទះរបស់គាត់ អញ្ចឹងយើងឃើញគាត់បានដើរមកដល់ផ្ទះរបស់គាត់
ដែលមានមាត់ទ្វារនិងមានជណ្តើរផងដែរ ក៏ប៉ុន្តែផ្ទះរបស់គាត់គឺទាបទេ អញ្ចឹងគាត់
ផ្ទះរបស់គាត់គឺអត់ខ្ពស់ទេ ដូច្នេះជណ្តើររបស់គាត់គឺមានតែពីរកាំតែប៉ុណ្ណោះ
អញ្ចឹងគឺងាយស្រួលឡើង អញ្ចឹងរូបភាពទី ៨ គឺបុរសម្នាក់នោះ គាត់បានយួរថង់អីវ៉ាន់ ឬក៏ថង់ម្ហូប
ដែលគាត់ទិញមកតាមផ្លូវអម្បាញ់មិញ មកផ្ទះរបស់គាត់ ដោយនៅក្នុងថង់ដែលគាត់យួរនោះ
គឺមានត្រី មានបាយ មានបន្លែ និងមានទឹកជ្រលក់ជាដើម ហើយគាត់យួរនៅដៃឆ្វេងរបស់គាត់
ដែលគាត់ដើរបណ្តើរ ញញឹមបណ្តើរ មកផ្ទះរបស់គាត់ ដែលយើងឃើញនៅមុខផ្ទះរបស់គាត់
គឺមានថូផ្កាចំនួនមួយ ហើយមានដើមឈើនៅក្នុងថូនោះផងដែរ
អញ្ចឹងបានន័យថាគាត់ប្រហែលជាស្រឡាញ់ដើមឈើ
ដូច្នេះគាត់បានដាំដើមឈើលម្អនៅខាងមុខផ្ទះរបស់គាត់
អញ្ចឹងគាត់ដាំដើមឈើដើម្បីលម្អនៅខាងមុខផ្ទះរបស់គាត់ ដែលបុរសម្នាក់នេះ
គាត់បានមកដល់ផ្ទះរបស់គាត់ បន្ទាប់ពីគាត់ទិញត្រីអាំងនិងម្ហូបផ្សេងៗនៅតាមផ្លូវរួចមក។

បន្ទាប់មកទៀតរូបភាពទី ៩ នៅក្នុងរូបភាពទី ៩ យើងឃើញ បន្ទាប់ពីគាត់ដើរមកដល់ផ្ទះហើយ
បុរសម្នាក់នោះ គាត់ក៏បានរៀបចំកន្លែងញ៉ាំបាយជាមួយនឹងមិត្តស្រីរបស់គាត់
ដែលយើងឃើញពួកគាត់ទាំងពីរនាក់គឺអត់ពាក់ស្បែកជើងទេ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

អញ្ចឹងបានន័យថានៅពេលដែលពួកគាត់នៅក្នុងផ្ទះ គឺគាត់អត់ពាក់ស្បែកជើងទេ
ដោយសារតែគាត់មិនចង់ឲ្យប្រឡាក់ផ្ទះរបស់គាត់ ម្យ៉ាងនៅក្នុង[...]នៅប្រទេសកម្ពុជា
គឺយើងអត់ដើរពាក់ស្បែកជើងចូលក្នុងផ្ទះទេ បានន័យថាយើងទុកស្បែកជើង
ស្បែកជើងរបស់យើងត្រូវទៅទុកនៅខាងក្រៅជានិច្ច
អញ្ចឹងយើងអត់ត្រូវពាក់ស្បែកជើងចូលក្នុងផ្ទះទេ ដែលជាក់ស្តែងយើងឃើញរូបភាពនេះ
គឺគេទាំងពីរនាក់ ដែលបុរសម្នាក់នោះ និងមិត្តស្រីរបស់គាត់ គឺគាត់អត់ពាក់ស្បែកជើងទេ
ហើយបុរសដែលជាមានវ័យ ២៣ ឆ្នាំនោះ គាត់បានក្រាលនូវកម្រាលមួយ
អញ្ចឹងគាត់ក្រាលកម្រាលដើម្បីអង្គុយញ៉ាំបាយ ហើយនារីដែលជាមិត្តស្រីរបស់គាត់
យើងឃើញគាត់ពាក់អាវដៃខ្លីពណ៌ស ខោជើងវែងពណ៌ខ្មៅ ហើយគាត់ចងសក់បួងទៅក្រោយ
ដោយដៃទាំងពីររបស់គាត់គឺកាន់ចានចំនួនមួយចំនួន អញ្ចឹងបានន័យថាគាត់កាន់ចាន
ដើម្បីយកមកដួសបាយ យកមកដាក់ម្ហូប ដើម្បីញ៉ាំ[...] សម្រាប់អាហារពេលល្ងាចនៅថ្ងៃនេះ។

បន្ទាប់មកទៀតរូបភាពទី ១០ នៅក្នុងរូបភាពទី ១០ យើងឃើញថា
បន្ទាប់ពីគាត់ក្រាលនូវកម្រាលរួចរាល់ហើយ
មិត្តស្រីរបស់គាត់ក៏បានយកចានមកដាក់នៅលើកម្រាលនោះ អញ្ចឹងគាត់បានទុកចង់ម្ហូប
ដែលគាត់បានទិញអម្បាញ់មិញនៅម្ខាង ហើយគាត់រៀបចានសិន
អញ្ចឹងយើងឃើញនារីដែលជាមិត្តស្រីនោះ គាត់កំពុង ដៃទាំងពីររបស់គាត់
អញ្ចឹងដៃទាំងពីររបស់គាត់គឺគាត់កំពុងតែ គាត់កំពុងតែកាន់ចានមួយចំនួន ដោយរៀបនៅលើកម្រាល
ចំណែកឯបុរសដែលមានវ័យ ២៣ ឆ្នាំនោះ អញ្ចឹងបុរសម្នាក់នោះ គាត់កំពុងតែកាន់ចានផង
និងសមផង អញ្ចឹងជាទូទៅយើងញ៉ាំបាយគឺយើងប្រើប្រាស់ស្លាបព្រាជាមួយនឹងសម
ដោយជាក់ស្តែងយើងឃើញបុរសម្នាក់នោះ ដៃស្តាំរបស់គាត់ គឺគាត់កំពុងតែកាន់ចាន
រីឯដៃឆ្វេងកំពុងតែកាន់ស្លាបព្រានិងសម ដើម្បីញ៉ាំជាមួយនឹងបាយ
ដោយពួកគេទាំងពីរនាក់កំពុងតែរៀបចាននៅលើកម្រាល ដោយយើងឃើញនៅលើកម្រាល
គឺមានចាន មានស្លាបព្រា មានសមផងដែរ អញ្ចឹងសមគឺវាអត់ជិតដូចស្លាបព្រាទេ
បានន័យថាស្លាបព្រាគឺវាជិត អត់មានប្រឡោះនោះទេ ដើម្បីហុតទឹកសម្លបាន
ចំណែកឯសមគឺវាមានធ្មេញស្រួចៗ អញ្ចឹងវាអត់ជិតទេ អញ្ចឹងវាអត់អាចដួសសម្លបានទេ
តែសមគឺយើងប្រើប្រាស់ដើម្បីជួយចាក់ជាសាច់ ឬក៏ជួយកាយបាយចូលក្នុងស្លាបព្រាបាន។

បន្ទាប់មកទៀតរូបភាពទី ១១ នៅក្នុងរូបភាពទី ១១ យើងឃើញថា
បន្ទាប់ពីពួកគាត់បានរៀបចានហើយ អញ្ចឹងបុរសម្នាក់នោះ
គាត់ក៏បានយកត្រីដែលគាត់បានទិញអម្បាញ់មិញមកដាក់ក្នុងចានផងដែរ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

អញ្ចឹងដោយសារតែត្រីគឺមានរូបរាងវែង ដូច្នេះគាត់ត្រូវប្រើប្រាស់ចានរាងពងក្រពើ
ចានរាងពងក្រពើដើម្បីដាក់ត្រីនោះ អញ្ចឹងយើងឃើញគាត់ដាក់ត្រីនៅលើចានរាងពងក្រពើ
រួចហើយគាត់កាន់មកដាក់នៅលើកម្រាល ដោយសារតែត្រីនោះ គឺជាត្រីអាំងហើយក្តៅ
ដូច្នេះយើងឃើញមានផ្សែងហុយចេញពីសាច់ត្រី ដែលបង្កឲ្យមានក្លិនឈ្ងុយ
អញ្ចឹងបានន័យថាផ្សែងដែលចេញពីសាច់ត្រីគឺធ្វើឲ្យមានក្លិនឈ្ងុយ បានន័យថាគួរឲ្យចង់ញ៉ាំ
អញ្ចឹងយើងឃើញស្ត្រីដែលជាមិត្តស្រីរបស់បុរសម្នាក់នោះ គាត់អង្គុយលុតជង្គង់នៅលើកម្រាល
ហើយបុរសដែលជាវ័យ ២៣ ឆ្នាំនោះ គាត់ក៏បានយកត្រីមកដាក់នៅលើកម្រាលដើម្បីញ៉ាំផងដែរ។

បន្ទាប់មកទៀតរូបភាពទី ១២ រូបភាពទី ១២ បន្ទាប់ពីគាត់រៀបចំត្រីហើយ បុរសម្នាក់នោះ
គាត់ក៏បានយកទឹកជ្រលក់ត្រី បានន័យថាទឹកជ្រលក់ យកមកចាក់ចូលទៅក្នុងចាន
ដោយសារតែទឹកជ្រលក់គឺគេខ្ចប់នៅក្នុងថង់ប្លាស្ទិក ដូច្នេះវានឹងពិបាកញ៉ាំ
ប្រសិនបើយើងអត់ចាក់ចូលក្នុងចាន អញ្ចឹងដើម្បីឲ្យវាមានរូបរាងស្អាត មើលទៅល្អមើលផង
និងស្រួលញ៉ាំផង យើងត្រូវចាក់ទឹកជ្រលក់ចូលទៅក្នុងចាន។
ជាធម្មតាទឹកជ្រលក់គឺមានច្រើនរសជាតិ បានន័យថាអ្នកខ្លះគាត់ចូលចិត្តទឹកជ្រលក់រសជាតិប្រៃ
អ្នកខ្លះចូលចិត្តទឹកជ្រលក់រសជាតិផ្អែម រីឯអ្នកខ្លះទៀតចូលចិត្តទឹកជ្រលក់រសជាតិជូរ
ដូច្នេះគាត់អាចកុម្ម៉ង់ទៅអ្នកលក់បានថាគាត់ចូលចិត្តរសជាតិអ្វី
ហើយពេលខ្លះទឹកជ្រលក់គឺមានរសជាតិហឹរផងដែរ ព្រោះប្រសិនបើអតិថិជនចូលចិត្តហឹរ
អ្នកលក់នឹងធ្វើទឹកជ្រលក់ដែលមានរសជាតិហឹរសម្រាប់គាត់
ដែលយើងអាចធ្វើទឹកជ្រលក់ទៅតាមចំណង់ចំណូលចិត្តរបស់យើង ប្រសិនបើយើងចង់បានជូរ
យើងគ្រាន់តែច្របាច់ក្រូចឆ្មារចូលទៅក្នុងទឹកជ្រលក់
គឺវាអាចធ្វើឲ្យទឹកជ្រលក់របស់យើងមានរសជាតិជូរបានជាការស្រេច អញ្ចឹងនៅក្នុងរូបភាពទី ១២
គឺគាត់បានចាក់ទឹកជ្រលក់របស់គាត់ចូលទៅក្នុងចានមួយ គឺកូនចាន ជាកូនចានមួយ
ដើម្បីងាយស្រួលជ្រលក់ត្រី ជ្រលក់សាច់ត្រី ដើម្បីញ៉ាំ អញ្ចឹងប្រសិនបើគាត់ទុកនៅក្នុងថង់ប្លាស្ទិក
គឺវាពិបាកនៅក្នុងការជ្រលក់ជាមួយនឹងសាច់ត្រីខ្លាំងណាស់។

បន្ទាប់មកទៀតរូបភាពទី ១៣ រូបភាពទី ១៣ បន្ទាប់ពីពួកគេរៀបចំចានម្ហូប
និងចានទឹកជ្រលក់រួចរាល់ហើយ ពួកគេក៏បានអង្គុយទល់មុខគ្នា
អញ្ចឹងយើងឃើញពួកគេកំពុងតែអង្គុយទល់មុខគ្នា ដោយស្ត្រីដែលជាមិត្តស្រីនោះ
គាត់អង្គុយលុតជង្គង់ ឬក៏អង្គុយបត់ជើង ដោយដៃទាំងពីរគឺដាក់នៅលើភ្លៅ
ចំណែកឯបុរសដែលមានវ័យ ២៣ ឆ្នាំនោះ គាត់អង្គុយពែនភ្នែន អញ្ចឹងជាធម្មតា
មនុស្សស្រីគឺគាត់តែងតែអង្គុយលុតជង្គង់ឬក៏អង្គុយបត់ជើង ចំណែកឯមនុស្សប្រុស

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

គាត់ចូលចិត្តអង្គុយពែនភ្នែន ហើយនៅចំខាងមុខរបស់ពួកគេ ឬក៏នៅកណ្ដាលពួកគេ
គឺមានត្រីចំនួនមួយ ដែលកំពុងតែហុយ និងមានក្លិនឈ្ងុយ ហើយមានចានបន្លែពីរចានផងដែរ
ដែលនៅក្បែរនោះ អញ្ចឹងពួកគេក៏ញ៉ាំត្រីជាមួយនឹងបន្លែ ផ្ទាប់ជាមួយនឹងបន្លែ
ដោយយើងឃើញគាត់ទាំងពីរនាក់ គឺអង្គុយនៅលើកម្រាល
ហើយមានកញ្ចប់ម្ហូបនៅក្បែរខ្លួនរបស់ពួកគេផងដែរ។ អញ្ចឹងជាទូទៅ គឺនៅកម្ពុជា
គឺយើងភាគច្រើនគឺយើងញ៉ាំបាយដោយប្រើប្រាស់កន្ទេល គឺយើងអត់ប្រើប្រាស់តុទេ អញ្ចឹងពេលខ្លះ
អ្នកខ្លះ ក្រុមគ្រួសារខ្លះ គាត់ញ៉ាំបាយនៅលើតុ បានន័យថាគាត់រៀបចំតុ
ហើយគាត់ដាក់បាយនៅលើតុ រួចក៏អង្គុយលើកៅអីដើម្បីញ៉ាំ ប៉ុន្តែភាគច្រើន ភាគច្រើននៅកម្ពុជា
គឺយើងអត់ប្រើប្រាស់តុទេ បានន័យថាយើងអត់ប្រើប្រាស់តុទេ គឺយើងក្រាលកន្ទេល
ឬក៏ការក្រាលកម្រាល អញ្ចឹងយើងក្រាលកន្ទេលនៅលើឥដ្ឋ ឬក៏នៅលើរនាបផ្ទះរបស់យើង
បន្ទាប់មកយើងញ៉ាំបាយនៅលើកន្ទេល អញ្ចឹងវាជាវប្បធម៌មួយរបស់កម្ពុជា
គឺយើងញ៉ាំបាយនៅលើកន្ទេល។

បន្ទាប់មកទៀតគឺរូបភាពទី ១៤ រូបភាពទី ១៤ គឺយើងឃើញថា
បន្ទាប់ពីពួកគាត់រៀបចំម្ហូបរួចរាល់អស់ហើយ អញ្ចឹងពួកគាត់ទាំងពីរក៏ចាប់ផ្ដើមបើកកញ្ចប់បាយ
អញ្ចឹងដោយសារតែគាត់អត់ដាំបាយទេនៅថ្ងៃនេះ ហើយគាត់ក៏អត់ធ្វើម្ហូបដែរ អញ្ចឹងគាត់ទិញបាយ
និងម្ហូបមកពីខាងក្រៅ អញ្ចឹងដោយសារតែបច្ចុប្បន្នមនុស្សយើងរវល់ច្រើន
ដូច្នេះយើងអត់មានពេលរៀបចំបាយម្ហូបខ្លួនឯងទេ បានន័យថាម្នាក់ៗគឺធ្វើការនិងរៀន
ហើយចូលមកដល់ផ្ទះយប់ៗជ្រៅពេក ដូច្នេះយើងអត់មានពេលធ្វើម្ហូបនិងដាំបាយញ៉ាំខ្លួនឯងទេ
អញ្ចឹងវិធីដែលល្អមួយគឺការទិញមកទីខាងក្រៅដើម្បីញ៉ាំ ដែលជាក់ស្ដែងនៅក្នុងរូបភាពទី ១៤
គឺបុរសម្នាក់នោះ គាត់បានទិញត្រីនិងទិញបាយមកពីហាងដែលលក់នៅតាមផ្លូវ
លក់នៅតាមចិញ្ចើមផ្លូវ ដើម្បីយកមកញ៉ាំ ដោយសារតែគាត់អត់មានពេលដាំបាយ
និងអត់មានពេលធ្វើម្ហូបដោយខ្លួនឯង ហើយរូបភាពទី ១៤ នេះ រូបភាពទី ១៤
គឺគាត់កំពុងតែហែកកញ្ចប់បាយ អញ្ចឹងជាទូទៅ កញ្ចប់បាយគឺតែងតែមានសំបក
ហើយនិងមានមាត់កញ្ចប់ អញ្ចឹងដើម្បីឲ្យចាក់បាយចេញពីកញ្ចប់នោះបាន
យើងត្រូវតែហែកមាត់កញ្ចប់បាយចេញ អញ្ចឹងយើងឃើញគាត់បានទាញកញ្ចប់បាយឡើងលើ
ទាញដើម្បីបកមាត់គម្របកញ្ចប់បាយឡើង ដើម្បីចាក់បាយចូលទៅក្នុងចាន។

បន្ទាប់មកទៀតរូបភាពទី ១៥ នៅក្នុងរូបភាពទី ១៥ យើងឃើញថា
បន្ទាប់ពីពួកគាត់រៀបចំរួចរាល់អស់ហើយ អញ្ចឹងគាត់រៀបចំរួចរាល់ទាំង រៀបចំបាយ រៀបចំម្ហូប
ក៏ដូចជារៀបចំទឹកជ្រលក់និងបន្លែសម្រាប់ផ្ទាប់ ឬក៏យើងហៅថាអន្លក់រួចរាល់ហើយ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

អញ្ចឹងគាត់ក៏ចាប់ផ្ដើមការញ៉ាំអាហារពេលល្ងាចរបស់គាត់តែម្ដង ដោយយើងឃើញនៅក្នុងរូបភាពទី ១៥ នេះ គាត់បានយកសមនិងស្លាបព្រាមកចាប់សាច់ត្រីញ៉ាំ អញ្ចឹងគាត់យកសមមកឆ្កឹះសាច់ត្រី រួចហើយយកសាច់ត្រីនោះមកដាក់លើស្លាបព្រា អញ្ចឹងគាត់យកសមដើម្បីចាក់សាច់ត្រី បេះសាច់ត្រី ដើម្បីយកមកដាក់លើស្លាបព្រាដើម្បីញ៉ាំ អញ្ចឹងជាទូទៅគឺត្រីគឺមានឆ្អឹងតូចៗ ដូច្នេះយើងញ៉ាំគឺត្រូវតែប្រុងប្រយ័ត្នបន្តិចជាមួយនឹងឆ្អឹង ព្រោះថាឆ្អឹងរបស់វាអាចនឹងមុត ឆ្អឹងវាគឺមុត ដូច្នេះប្រសិនបើយើងអត់ប្រយ័ត្នទេ យើងអាចស្លាក់ឆ្អឹងបាន អញ្ចឹងយើងអាចស្លាក់ឆ្អឹងនៅក្នុងបំពង់ក ឬក៏ឆ្អឹងអាចមុតអណ្ដាត ឬក៏មុតអញ្ចាញធ្មេញរបស់យើងនៅពេលដែលយើងញ៉ាំមិនបានប្រុងប្រយ័ត្ន ដោយសារតែឆ្អឹងរបស់វាតូចៗ ដូច្នេះមុនពេលដែលយើងញ៉ាំត្រីគឺយើងត្រូវបេះឆ្អឹងវាចេញសិន ឬក៏យើងញ៉ាំតែសាច់វាទេ គឺយើងអត់ត្រូវទំពាទាំងឆ្អឹងនោះទេ ដោយសារតែយើងអាចនឹងមុត ឬក៏អាចយើងឲ្យស្លាក់បាន។ អញ្ចឹងយើងមើលរូបភាពទី ១៥ នេះ គឺគាត់អត់ញ៉ាំទាំងឆ្អឹងទេ បានន័យថាគាត់យកសមមកកោសយកសាច់ត្រីចេញពីឆ្អឹងរបស់ត្រី ហើយគាត់យកសមនោះ ដែលជាប់សាច់ត្រី យកមកដាក់នៅលើស្លាបព្រា អញ្ចឹងដើម្បីញ៉ាំជាមួយនឹងស្លាបព្រា អញ្ចឹងជាទូទៅកម្ពុជា ឬក៏ប្រជាជនខ្មែរ គឺគាត់ញ៉ាំបាយនឹងស្លាបព្រាជាមួយនឹងសម គឺយើងអត់ចូលចិត្តប្រើចង្កឹះនោះទេ ដែលយើងឃើញត្រីអាំងនៅក្នុងនេះគឺមានក្លិនឈ្ងុយ គឺមានក្លិនឈ្ងុយ ដោយមានផ្សែងហុយចេញពីចាន ដែលវានៅក្ដៅៗផងដែរ ដោយសារតែគាត់ទិញគឺត្រីដែលទើបនឹងអាំង។

បន្ទាប់មកទៀតរូបភាពទី ១៦ នៅក្នុងរូបភាពទី ១៦ យើងឃើញថា បន្ទាប់ពីគាត់ញ៉ាំត្រីអាំងហើយ គាត់ក៏បានញ៉ាំជាមួយនឹងបន្លែផងដែរ អញ្ចឹងជាទូទៅត្រីអាំងគឺយើងតែងតែញ៉ាំជាមួយនឹងបន្លែ ឬក៏យើងហៅថាអន្លក់ ដើម្បីបន្ថែមរសជាតិវាឲ្យកាន់តែឆ្ងាញ់ ព្រោះត្រីអាំងគឺមានទឹកជ្រលក់ ដូច្នេះទឹកជ្រលក់គឺយើងញ៉ាំជាមួយបន្លែផងដែរ ដើម្បីឲ្យឆ្ងាញ់ ឲ្យកាន់តែឆ្ងាញ់ អញ្ចឹងបន្លែដែលយើងញ៉ាំជាមួយផ្ទាប់ យើងហៅថាផ្ទាប់ជាមួយនឹងត្រីអាំង ជាមួយនឹងទឹកជ្រលក់ យើងហៅបន្លែនោះថាអន្លក់ អញ្ចឹងអន្លក់ជាទូទៅគឺជាបន្លែខ្ចីៗ មានដូចជាត្រសក់ មានដូចជាស្ពៃ មានដូចជីរជាដើម អញ្ចឹងយើងអាចញ៉ាំជាមួយនឹងសាច់ត្រី ផ្ទាប់ជាមួយនឹងសាច់ត្រី ផ្ទាប់ជាមួយនឹងទឹកជ្រលក់ ហើយយើងយកមកញ៉ាំ ដែលយើងហៅថាវាជាអន្លក់។

បន្ទាប់មកទៀតរូបភាពទី ១៧ នៅក្នុងរូបភាពទី ១៧ យើងឃើញថា ពួកគេទាំងពីរនាក់បានញ៉ាំបាយរួចរាល់ហើយ ហើយចំពោះសាច់ត្រីមួយដែលគេទិញមកនេះ គឺមានរសជាតិឆ្ងាញ់យ៉ាងខ្លាំង ដូច្នេះគេញ៉ាំបាយអស់ច្រើន អញ្ចឹងគេញ៉ាំបាយអស់ច្រើន អស់ទាំងពីរកញ្ចប់តែម្ដង ហើយអន្លក់ដែលនៅលើកម្រាលគឺអត់មានទៀតទេ បានន័យថាពួកគេញ៉ាំអស់ទាំងអស់ គឺអស់ទាំងអន្លក់ អស់ទាំងទឹកជ្រលក់ជាមួយនឹងសាច់ត្រីផងដែរ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ដោយយើងឃើញនៅក្នុងរូបភាពទី ១៧ នេះ គឺសាច់ត្រីគឺនៅសល់តែឆ្អឹងនោះទេ
អញ្ចឹងអត់មានសាច់ទៀតទេ បានន័យថាពួកគាត់ទាំងពីរគឺញ៉ាំសាច់ទាំងអស់
អញ្ចឹងពួកគាត់ទុកតែឆ្អឹងតែប៉ុណ្ណោះនៅក្នុងរូបភាពទី ១៧ នេះ
ដោយពួកគាត់ទាំងពីរនាក់ឆ្អែតទាំងពីរនាក់តែម្តង ដោយយើងឃើញនារី
ដែលជាមិត្តស្រីរបស់បុរសម្នាក់ហ្នឹង គាត់អង្គុយបត់ជើងនៅលើកម្រាល
ហើយយកដៃម្ខាងច្រត់ទៅលើឥដ្ឋ ដៃម្ខាងទៀតខ្ទប់ពោះរបស់គាត់
ដែលបញ្ជាក់ថាគាត់កំពុងតែឆ្អែតយ៉ាងតឹងពោះ។ អញ្ចឹងគាត់អង្គុយសម្រាក
គាត់អត់ទាន់ធ្វើការងារអ្វីផ្សេងទេ ដើម្បីឲ្យស្រកពោះសិន អញ្ចឹងយើងហៅថាឲ្យស្រកពោះ
បានន័យថាឲ្យពោះរបស់គាត់ធូរ លែងសូវតឹងសិន ទើបគាត់ធ្វើការបន្ត ចំណែកឯបុរសដែលមានវ័យ
២៣ ឆ្នាំនោះ គាត់ក៏ឆ្អែតដូចគ្នា អញ្ចឹងគាត់ក៏ញ៉ាំបាយបានឆ្អែតដូចគ្នា
ដូច្នេះគាត់ក៏បានយកដៃរបស់គាត់អង្អែលពោះរបស់គាត់ ហើយគាត់អង្គុយបញ្ឈរជង្គង់ឡើង
ដើម្បីសម្រួលខ្លួន ឲ្យក្រពះរបស់គាត់រំលាយអាហារបានល្អ។ អញ្ចឹងគាត់អង្គុយបញ្ឈរជង្គង់
ហើយទម្រេតខ្លួនទៅខាងក្រោយបន្តិច ដោយយកដៃច្រត់ទៅលើកម្រាល ដើម្បីទប់ខ្លួនឲ្យបាននឹង
អញ្ចឹងដើម្បីរក្សាលំនឹងលើខ្លួនគាត់ គាត់យកដៃច្រត់ទៅលើកម្រាល ដើម្បីអង្គុយសម្រាក
ដូច្នេះគាត់សម្រាកសិន បន្ទាប់ពីគាត់ញ៉ាំបាយរួចរាល់ហើយ
ដោយសារតែគាត់មានអារម្មណ៍ថាឆ្អែតខ្លាំងពេក អញ្ចឹងមុននឹងធ្វើការបន្ត គាត់ត្រូវតែសម្រាកបន្តិច
ដើម្បីឲ្យធូរពោះងាយស្រួលក្នុងការធ្វើការផ្សេងទៀត បន្ទាប់ពីគាត់ញ៉ាំបាយរួច។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.